សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៦៦
ថ្ងៃទី២៦-៤-២០១១
សាលដីកា
លេខ: ៧០ ក្រVI.ប
ថ្ងៃទី០៩-៩-២០១៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី០៩-៩-២០១៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់ នៃរឿងព្រហ្មទណ្ឌលេខ ៣៦៦ ចុះថ្ងៃទី២៦-៤-២០១១ រវាង:

- ជនជាប់ចោទ:

១- ឈ្មោះ [redacted] លីស្រោង ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] របររកស៊ី មន្ត្រីចូលនិវត្តន៍ មានប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

២- ឈ្មោះ [redacted] សុខុម ភេទស្រី អាយុ៥៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] របររកស៊ី នៅផ្ទះ មានប្តីឈ្មោះ [redacted] មានកូន០៥នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

- មានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] សំអឿន ។

ជាប់ចោទពីបទ: លួចលក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៤-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ មានអាសយដ្ឋានផ្ទះលេខ [redacted] ។

- មានមេធាវីការពារសិទ្ធិឲ្យ លោក [redacted] ម៉ាច ។

- តាមបណ្តឹងទាស់លេខ ១៤ ចុះថ្ងៃទី២៤-០២-២០១៤ របស់លោក [redacted] ងួនគា និង [redacted] ម៉ាច ជាមេធាវីទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភារ៉ា ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ៩៥ ក្រ៥.ប ចុះថ្ងៃទី៣១-១២-២០១៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

<u>៦រឿងហេតុមានដូចតទៅ:</u>

កាលពីថ្ងៃទី១១-០៩-២០០៨ ឈ្មោះ [redacted] ស៊ីណាត តំណាងឲ្យឈ្មោះ [redacted] សុភារ៉ា បានដាក់ពាក្យបណ្តឹងចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីប្តឹងពីលើឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម ពីបទ: លួចលក់អចនវត្ថុរបស់អ្នកដទៃដោយមូលហេតុឈ្មោះ [redacted] សុភារ៉ា ត្រូវជាកូនបានឲ្យឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម ត្រូវជាឪពុកម្តាយជួយទិញដីដែលមានទីតាំងនៅតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល មានទំហំសរុប ៣០.៤៥៨,៣៩ម៉ែត្រការ៉េ ក្នុងការទិញនេះឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម ដាក់ឈ្មោះគាត់ជាអ្នកទិញតែឈ្មោះ [redacted] សុភារ៉ា មិនឯកភាពទើបកាត់ឈ្មោះដាក់ជារបស់ខ្លួនវិញ នៅចំពោះមុខសាលាឃុំឈ្វាំង នៅថ្ងៃទី១៦-១០-២០០៦ ដោយមានមេភូមិឈ្មោះ [redacted] ការិន ជាអ្នកដឹងឮ ។ នៅថ្ងៃទី០២-០៤-២០០៨ ឈ្មោះ [redacted] លីស្រ៊ាង និងប្រពន្ធឈ្មោះ ខៀវ សុខុម បានយកដីនេះទៅលក់ឲ្យឈ្មោះ [redacted] ភៀង និងឈ្មោះ [redacted] រស់ យកប្រាក់ជាប្រយោជន៍របស់ខ្លួន ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៦(ឃ) ចុះថ្ងៃទី០៩-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ផ្តន្ទាទោស:

- ឈ្មោះ [redacted] លីស្រ៊ាង ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] សុខុម ភេទស្រី អាយុ ៥៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ០១ឆ្នាំ (មួយឆ្នាំ) ពីបទ: លួចលក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

២- បង្គាប់ឲ្យជនជាប់ចោទ សងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០.០០០.០០០ (ដប់លានរៀល) សំណូមពរលើសពីនេះ ត្រូវបដិសេធចោល ។

៤២៦

៣- សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៦៧០ ចុះថ្ងៃទី០៨-១០-២០១០ របស់ឈ្មោះ [redacted] សុខុម និង [redacted] លីស្រ៊ាង នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៦(ឈ) ចុះថ្ងៃទី០៩-៩-២០១០ ត្រង់ចំណុច សេចក្តីសាលក្រមទាំងមូល ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៩៥ ក្រ៥.ប ចុះថ្ងៃទី៣១-១២-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា៖

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៧០ ចុះថ្ងៃទី០៨-១០-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៥៦(ឈ) ចុះថ្ងៃទី០៩-៩-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់ ។

៣- ឲ្យឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម រួចផុតពីបទចោទ លួចលក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៤-២០០៨ តាមបញ្ញត្តិមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣-១២-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង និងឈ្មោះ [redacted] សុខុម កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈនៅថ្ងៃទី៣១-១២-២០១៣ ។

- បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងទាស់លេខ ១៨ ចុះថ្ងៃទី២៤-០២-២០១៤ របស់លោក [redacted] ងួនគា និង [redacted] ម៉ាច ជាមេធាវីទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព៉ា ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ៩៥ ក្រ៥.ប ចុះថ្ងៃទី៣១-១២-២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៩-១០-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៣-០២-២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង, [redacted] សុខុម (វត្តមាន)
- មានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក [redacted] សំអឿន (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)
- មានមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី លោក [redacted] ម៉ាច (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

- ជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង និង [redacted] សុខុម បានឆ្លើយថា ខ្លួនសុំរួចខ្លួន ដូចការសម្រេចលើកមុន ។ ដូច្នេះសំណូមពរ សុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩៥ ក្រ៥.ប ចុះថ្ងៃទី៣១-១២-២០១៣ របស់សាលាឧទ្ធរណ៍ ទុកដដែល ។

តំណាងមហាអយ្យការសន្និដ្ឋានថា:

បណ្តឹងនេះ គឺជាបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី តំណាងមហាអយ្យការ យល់ឃើញថា ទុកជូនក្រុមប្រឹក្សាពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ តាមមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋាន:

- លោក សុក សំអឿន មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា កាលសវនាការលើកមុនលោកមេធាវី [redacted] ម៉ាច គាត់ចូលមកតវ៉ាឲ្យកូនក្តីគាត់ ដោយសារ តំបាំងមុខកូនក្តីគាត់ ហើយគាត់បានប្តឹងទាស់ ដូច្នេះពេលនេះទោះបីលោក [redacted] ម៉ាច ចូល មកក៏ឥតប្រយោជន៍ដែរ លុះត្រាតែដើមបណ្តឹងផ្ទាល់ទើបបាន ។ បណ្តឹងនេះធ្វើផ្ទុយនឹង មាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដូច្នេះសូមតុលាការពិចារណាតាមច្បាប់ ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

សាលាឧទ្ធរណ៍យល់ឃើញថា:

- បណ្តឹងទាស់លេខ ១៤ ចុះថ្ងៃទី២៤-០២-២០១៤ របស់លោក [redacted] ងួនគា និង [redacted] ម៉ាច ជាមេធាវីទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភាព បណ្តឹងនេះធ្វើឡើង ក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែបណ្តឹងទាស់របស់ មេធាវីទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសាលាឧទ្ធរណ៍អញ្ជើញ និងកោះហៅ តាមគំនិតផ្តួចផ្តើមរបស់អគ្គព្រះរាជអាជ្ញាយ៉ាងត្រឹមត្រូវរួចហើយ តែមិនចូលមកបង្ហាញខ្លួន នៅពេលសវនាការ តុលាការប្រកាសថា បណ្តឹងទាស់ត្រូវទុកជាអសារឥតការ ម្យ៉ាងទៀត រឿងក្តីនេះត្រូវបានសាលាឧទ្ធរណ៍សម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង និង ឈ្មោះ [redacted] សុខុម សម្រេចឲ្យរួចខ្លួនពីបទចោទប្រកាន់ ពីបទ: លួចលក់អចលនទ្រព្យអ្នក ដទៃ ដូចនេះសាលាឧទ្ធរណ៍ពុំគប្បីលើកមកពិចារណាឡើយ ដោយហេតុថា ផ្ទុយមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤២៤

## ហេតុដូច្នេះ

## ខនិច្ឆ័យសេចក្ដី:

១- សាលាឧទ្ធរណ៍ប្រកាសថា បណ្ដឹងទាស់លេខ ១៨ ចុះថ្ងៃទី២៨-០២-២០១៤ របស់លោក [redacted] ងួនតា និង [redacted] ម៉ាច ជាមេធាវីទទួលសិទ្ធិពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភារ៉ា ត្រូវទុកជាអសារឥតការ តាមមាត្រា ៤១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩-៩-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីស្រ៊ាង និង [redacted] សុខុម និងមេធាវីការពារសិទ្ធិ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារសិទ្ធិ ។

- បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

| បានឃើញ<br>ប្រធានសាលាឧទ្ធរណ៍ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម<br>ភ្នំពេញ ថ្ងៃ...ខែ...មករា....ឆ្នាំ ២០១៥<br>ក្រឡាបញ្ជី |
|---|---|
| [redacted] | [redacted] |

៤២៨